# រឿង មហាចោរនៅទល់ដែន

## ភាគទី១១

មានទន្ទបំផាយសេះយ៉ាងលឿនកន្ទាលទីងងឹតឆ្ពោះទៅកាន់គេហដ្ឋានព្រះកម្ពុត។ ទុក្ខដែលកើតអំពីមរណភាពវិសេសក្លាហាននៅញាំញីចិត្តអ្នកពុំចេះចប់ពុំចេះហើយ។ មរណភាពតែមួយនេះ ធ្វើឲ្យអ្នកអាណិតអាសូរដល់បិតាក្មេកដែលចាកស្ថានទៅផង ឲ្យអ្នកអាណិតដល់នាងទេវីជាភរិយាសំនប់ដែលរស់នៅនោះផង។

ទុក្ខទាំងពីរប្រភេទសឹងមានទម្ងន់ស្មើគ្នា។

អ្នកអាណិតវិសេសក្លាហានដោយបុគ្គលនេះស្លាប់ទៅមានទឹកមុខញញឹមស្រស់ប៉ប្រិម ដូចកត្រព្រះពុទ្ធដែលចូលព្រះនិព្វាន។ អ្នកអាណិតនាងទេវីដោយស្រីឆើតឆាយបានបង្ហូរទឹកភ្នែកសស្រាក់ ទឹកភ្នែកនេះហាក់នៅសើមៗក្នុងដួងវិញ្ញាណរបស់អ្នក។ សេះបោលសម្រុកទៅមុខយ៉ាងលឿន កាត់ព្រៃ និង វាល ដូចព្រួញព្រហ្មរបស់ព្រះនរាយណ៍។ គេឮសូរស្នឹកឈើ និងមែកឈើដែលបាក់ប្រាវៗ។ មិនយូរប៉ុន្មានមានទន្ទមើលឃើញកំពែងអាសនបិតាខ្លួន។ អ្នកបោះពួយតម្រង់ទៅមាត់ទ្វារ។ អ្នកយាមធ្វើសញ្ញាគោរពយ៉ាងស្វាហាប់។ លុះអ្នកជិះសេះនេះទៅដល់បន្ទាយហើយ ក៏លោតចុះពីលើខ្នងសេះដោយរួសរាន់បន្ទាន់ចិត្ត។ សេនាម្នាក់ក៏ស្ទុះមកគោរពជាលើកទីពីរ។ មនទន្ទស្គាល់ក្នុងទីងងឹតថាជាសេនារបស់ខ្លួន ក៏មានវាចាខ្សឹបៗថា៖

- បងកោប បងឯងមានដឹងរឿងអ្វីប្លែកក្នុងផ្ទះខ្ញុំទេ ?

គឺមនុស្សម្នាក់រូបតូច ខ្នងខុបបាក់ជាពីរ ។ មនុស្សនេះឆ្លើយដោយនឹងនួនវិញថា៖

- បាទទេ ! អត់មានរឿងអ្វីទេ ! តែមុននេះបន្តិចមានឃើញទាហានម្នាក់ជិះសេះមកដល់ទីនេះ រួចចូលទៅក្នុងបន្ទប់ឪពុករបស់លោកគ្រូ ។ ខ្ញុំឃើញសេះ និង អ្នកជិះនោះបែកញើសជាបខ្លួន។ ប្រហែលជាមានការអ្វីប្លែកមកពីក្រៅហើយមើលទៅ។
- ឪពុកខ្ញុំនៅទេ ?
- នៅហ្នឹង!
- ចុះបងកោប ឯងមានឮសូរមាត់គាត់និយាយអ្វីទេ ?

អត្ថបទដោយ៖ មាស សុភាព

- ទេ ! អត់ទេ !
- តាំងពីល្ងាចមក គាត់សម្រាន្តហើយ រឺ នៅ?
- នៅ ! ម៉េចក៏លោកគ្រូសួរដូច្នោះ ?
- ការផ្ទាល់ខ្លួន !
- ការអ្វី ?

មានឮទះស្នាកោបមួយផ្ទង់ សើច ធ្វើដោយមេត្រីភាព៖

- ចាំថ្ងៃក្រោយខ្ញុំនិយាយប្រាប់។ ឥឡូវយកសេះខ្ញុំទៅទុកចុះ។ នាយកោបមិនអស់ចិត្ត ចាប់បង្ហៀរសេះបណ្តើរ សួរបណ្តើរទៀតថា៖
- ការធំ រឺ ការតូច ? ការចិត្ត រឺ ការនគរ ? ការសប្បាយ រឺ ការច្បាំង ?
- ការចិត្ត តែឥឡូវនេះខ្ញុំប្រញាប់ណាស់ ប្រញាប់ទៅជួប នឹង ឪពុករបស់ខ្ញុំ។
- បានជាខ្ញុំចង់ដឹង ពីព្រោះខ្ញុំចេះតែញាក់ភ្នែកឆ្វេងព្រើត១...!
- ឆ្កួត !
- បើមានរឿងអ្វី សូមលោកគ្រូអាណិតប្រាប់ខ្ញុំឲ្យឆាប់ផងណា !..
- យល់ព្រម

មានឮក៏ស្ទុះឡើងកាំជន្តើរទៅលើផ្ទះ។ នាយកោបក៏ដឹកសេះយកទៅទុក។ មានឮដើរយ៉ាងមាំមួនចូលទៅក្នុងបន្ទប់ព្រះកម្ពុត។ គឺជាបន្ទប់មួយធំ ជញ្ជាំងលាបពណ៌បៃតងខ្ចីស្រស់។ នៅជញ្ជាំងនីមួយៗមានព្យួរផ្ទាំងគំនូរចាស់ៗ គូរដោយដៃសិប្បករយ៉ាងចំណាននៃសម័យព្រងនាយនោះ។ នៅលើក្តារ គឺកម្រាលល្អធេតឆាយរំលេចដោយរូបភាពសត្វផ្សេងៗ និងរុក្ខាលតាវល្លិប្លែកៗដោយពណ៌ស លឿង ក្រហម បីដូចពណ៌ធម្មជាតិមែនៗ។ ក្រៅពីនេះចក្ខុឃើញចាប់ក្ខឹកស្នប់ស្ញែងដល់តុ ទូ កៅអី ដែលរៀបចំយ៉ាងប្រពៃ។ វត្ថុទាំងអស់សុទ្ធសឹងតែលាងជុសខាត់ស្អាតរលោងរលើបស្ទើរឆ្លុះមុខបាន។ គ្រឿងលំអទាំងពួងមានកែវកងជាដើម សឹងធ្វើអំពីប្រាក់ និង មាសយ៉ាងរុងរឿង។ នៅខាងមុខបន្ទប់ដ៏ស្កុកស្កម្ភនេះ ព្រះកម្ពុតកំពុងធ្វើការ អង្គុយសរសេរនៅលើតុធំមួយ។ គឺជាមនុស្សម្នាក់ប្រមាណ ៥០ឆ្នាំ ភ្នែកលៀនសក់ស្កូវ

អត្ថបទដោយ៖ មាស សុភាព

ល្បាយអាចម៍ខ្លា ថ្លាសខ្ពស់ៗ នៅពីក្រោយខ្នងស្តេចសឹកនេះ គេសង្កេតឃើញអាវុធគ្រប់បែប គ្រប់យ៉ាងដែលព្យួរនៅជញ្ជាំង មានកាំបិតស្នៀត ដាវ ផ្គួ ព្រួញ ខែល ជាដើម។

(សូមរង់ចាំតាមដានភាគទី១២ នៅសប្តាហ៍ក្រោយ)

អត្ថបទដោយ៖ មាស សុភាព